**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**

**លេខ :** ១៥៧ សជណ.ប្រ

## សេចក្តីជូនដំណឹង
## ស្តីពី
## ការអនុវត្តវិធានការបង្ការ និងទប់ស្កាត់ការរីករាលដាលជំងឺ កូវីដ១៩ ក្នុងព្រឹត្តិការណ៍ «សហគមន៍ ២០ កុម្ភៈ» នៅទីស្តីការគណៈរដ្ឋមន្ត្រី និងតាមបណ្តាអង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រី

យោងប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា កាលពីយប់ថ្ងៃចន្ទ ១០រោច ខែផល្គុន ឆ្នាំជូត ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៨ ខែមីនា ឆ្នាំ២០២១ ដើម្បីចូលរួមចំណែកបង្ការនិងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ ក្នុងព្រឹត្តិការណ៍ «សហគមន៍ ២០ កុម្ភៈ» ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ទីស្តីការគណៈរដ្ឋមន្ត្រីសូមដាក់ចេញនូវវិធានការមួយចំនួនដល់ ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក កម្មករ និងកងកម្លាំងទាំងអស់ក្នុងទីស្តីការគណៈរដ្ឋមន្ត្រី និងតាមបណ្តាអង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រី ដូចខាងក្រោម៖

១- បុគ្គលទាំងឡាយណាដែលមានជាប់ពាក់ព័ន្ធដោយផ្ទាល់ក្តី និងដោយប្រយោលក្តីទៅនឹងព្រឹត្តិការណ៍ «សហគមន៍ ២០ កុម្ភៈ» ត្រូវសម្រាកពីការងារមួយរយៈសិន ដើម្បីធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃ និងអញ្ជើញទៅធ្វើតេស្តនៅតាមទីតាំងនិងពេលវេលាដែលបានកំណត់ ព្រមទាំងត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមវិធានការនានារបស់ក្រសួងសុខាភិបាល។ ក្នុងករណីផ្ទះសម្បែងមានលក្ខណៈតូចចង្អៀត ឬគ្មានទីកន្លែងសមស្របសម្រាប់ការធ្វើចត្តាឡីស័កទេនោះ ត្រូវទាក់ទងជាបន្ទាន់ទៅក្រសួងសុខាភិបាល ឬរដ្ឋបាលរាជធានីភ្នំពេញ ដើម្បីធ្វើចត្តាឡីស័ក។

២- ផ្អាករាល់កិច្ចប្រជុំនានានៅទីស្តីការគណៈរដ្ឋមន្ត្រី រយៈពេល៧ថ្ងៃ គិតចាប់ពីថ្ងៃទី៩ ខែមីនា ឆ្នាំ២០២១តទៅ លើកលែងតែមានករណីចាំបាច់ដោយមានការណែនាំដ៏ខ្ពង់ខ្ពស់បំផុតពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

៣- អង្គភាពនីមួយៗត្រូវរៀបចំឱ្យមានការផ្លាស់វេនគ្នាមកធ្វើការប្រចាំថ្ងៃ ដោយធ្វើការបែងចែកក្នុង១ក្រុមមិនឱ្យលើសពី ១០% នៃចំនួនមន្ត្រីក្នុងអង្គភាព។ ចំពោះមន្ត្រីរាជការទាំងឡាយណា ដែលមិនមានវេនត្រូវមកកន្លែងធ្វើការ សូមស្ថិតនៅក្នុងផ្ទះបំពេញភារកិច្ចរៀងៗខ្លួន តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (អនឡាញ) និងកុំធ្វើដំណើរទៅទីឆ្ងាយប្រសិនបើគ្មានការចាំបាច់បន្ទាន់។



CS Scanned with CamScanner

៤- ថ្នាក់ដឹកនាំជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក ប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែលដែលមានសិទ្ធិសម្រេចលើការងារ ត្រូវមានវត្តមានជាចាំបាច់នៅក្នុងការិយាល័យរៀងរាល់ថ្ងៃធ្វើការ។

៥-គ្រប់ច្រកចេញចូលរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងតាមបណ្តាអង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រីទាំងអស់ ត្រូវរៀបចំឱ្យមានសន្តិសុខ មន្ត្រីប្រចាំការ ដើម្បីស្កេន QR Code ទប់ស្កាត់កូវីដ-១៩ ( Stop Covid-19) និងវាស់កំដៅនូវរាល់អ្នកចេញចូលទាំងអស់ជាប្រចាំទាំងពេលចូល និងពេលចេញទៅវិញ ដោយគ្មានការលើកលែងជាដាច់ខាត។ ក្នុងករណីពិនិត្យឃើញថា មានបុគ្គលណាមានកំដៅចាប់ពី ៣៧,៥ អង្សាសេឡើងទៅ គឺ មិនត្រូវអនុញ្ញាតឱ្យចូលឡើយ និងត្រូវណែនាំសាមីខ្លួនទំនាក់ទំនងជាមួយក្រសួងសុខាភិបាលតាមទូរសព្ទលេខ ១១៥ ដើម្បីយកសំណាកទៅធ្វើតេស្តជាបន្ទាន់។

៦-ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់បំផុតតាមវិធានការនានារបស់ក្រសួងសុខាភិបាល ជាពិសេសត្រូវពាក់ម៉ាស លាងដៃជាមួយទឹកសាប៊ូ ទឹកអាល់កុល ឬជែល និងពាក់ស្រោមដៃរាល់ពេលចរាចរឯកសារ ព្រមទាំងអនុវត្តវិធានការការពារតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី គឺ **៣ការពារ និង៣កុំ**។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក កម្មករ និងកងកម្លាំងទាំងអស់ក្នុងទីស្តីការគណៈរដ្ឋមន្ត្រី និងតាមបណ្តាអង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រី ជ្រាប និងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ១១កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**ចម្លងជូន៖**
- ក្រសួងសុខាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានីភ្នំពេញ
- គ្រប់អង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រី
- ឯកសារ កាលប្បវត្តិ



CS Scanned with CamScanner